



ថ្ងៃព្រហស្បតិ៍ ១៥ រោច ខែអាសាឍ ដល់ថ្ងៃសុក្រ ០១ កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ពស ២៥៦៦ ត្រូវថ្ងៃទី២៨ ដល់ ២៩ ខែកក្កដា ឆ្នាំ២០២២ នៅបន្ទប់ប្រជុំ នៃភូមិគ្រឹះនាងគង្ហីង ខេត្ត កំពង់ចាម មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ សហការជាមួយ គំរោង EpiC, FHI 360 បានរៀបចំ វគ្គតម្រង់ទិសស្ដីពី:

***ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យ*** (NPD System) ***សម្រាប់យុទ្ធវិធីជំរុញខ្លាំងក្លា បង្ការ ថែទាំ និងព្យាបាលបន្តដល់ក្រុមប្រឈមនឹងការឆ្លងមេរោគអេដស៍*** (B-CoPCT) ដែលមានគោលបំណង:

- ការធ្វើបច្ចុប្បន្នភាពពីកម្មវិធីបង្ការមេរោគអេដស៍តាមល្បាក់សេវានៅក្នុងប្រទេសកម្ពុជា ជំរុញនិង តាមដានទិន្នន័យដែលបានក្នុងប្រព័ន្ធ **NPD**។
- យល់ដឹងពីសូចនករសំខាន់ៗ រំហូរបាយការណ៍នៃការអនុវត្ត **B-CoPCT** ពីសហគមន៍ រហូតដល់ថ្នាក់ជាតិ និងប្រើប្រាស់ប៉ាណូបរិធាន ។
- អាចប្រើប្រាស់ឧបករណ៍ វិភាគទិន្នន័យ បង្ហាញជាក្រាប និងនៅលើផែនទី ព្រមទាំងអាចប្រើប្រាស់ទិន្នន័យ ដើម្បីធ្វើអោយប្រសើរឡើងនូវអន្តរាគមន៍បង្ការ។

ដែលមានសិក្ខាកាមជា ប្រធានកម្មវិធីអេដស៍ មន្ត្រីគ្រប់គ្រងទិន្នន័យ មកពី ខេត្តបន្ទាយមានជ័យ បាត់ដំបង សៀមរាប កណ្តាល ព្រះសីហនុ កំពង់ស្ពឺ កំពង់ចាម រាជធានីភ្នំពេញ និង អង្គការ **CWPD, MHC, KHANNA, RHAC, FI , AHF , FHI 360 .**

ពិធីបើក នាព្រឹកថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០២២ សិក្ខាសាលានេះបានចាប់ផ្តើមនៅ ម៉ោង ៨និង ៣០នាទី ព្រឹក

- មតិចំណាប់អារម្មណ៍ដោយ**លោក សូ គឹមហៃ** មន្ត្រីបច្ចេកទេសជាន់ខ្ពស់ផ្នែកបង្ការមេរោគអេដស៍នៃគម្រោង EpiC, FHI 360
- មតិចំណាប់អារម្មណ៍ដោយ**លោក វេជ្ជ. កាអឿន ចិត្រា** អនុប្រធានការិយាល័យបច្ចេកទេស និងជាប្រធានផ្នែកគ្រប់គ្រងទិន្នន័យ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
- មតិចំណាប់អារម្មណ៍និងពិធីបើក សិក្ខាសាលា ដោយឯកឧត្តម **វេជ្ជ គឹម សួគីរុណ** ប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពង់ចាម ។

